**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**លេខ**......១៩៤......**កប/ប្រក**

**ក្រសួងសុខាភិបាល**

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការបង្កើតគណៈកម្មការរៀបចំយន្តការនៃការទូទាត់សេវាសុខាភិបាល

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
## និង
## រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- អនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ៦៧ អនក្រ-បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមិនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម
- យោងតាមការចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ ១-**

បង្កើតគណៈកម្មការរៀបចំកំណត់យន្តការនិងបែបបទទូទាត់សេវាសុខាភិបាលសម្រាប់គម្រោងដែលស្ថិតនៅក្រោមបេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះ

បណ្តាលវិជ្ជាជីវៈ សម្រាប់កម្មករនិយោជិតដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១.វេជ្ជ ប៉ុក វណ្ណថាត | អនុប្រធានន.ពេទ្យការងារ<br>នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ប្រធាន |
| ២.វេជ្ជ. ស៊ុំ សោភ័ណ | នាយករងបេឡាជាតិរបបសន្តិសុខសង្គម<br>នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | អនុប្រធាន |
| ៣.វេជ្ជ. សុខ ស្រ៊ុន | អនុប្រធានន.មន្ទីរពេទ្យ<br>នៃក្រសួងសុខាភិបាល | អនុប្រធាន |
| ៤.វេជ្ជ. កុល ហោរ៉ូ | អនុប្រធានន.ការពារសុខភាព<br>នៃក្រសួងសុខាភិបាល | អនុប្រធាន |
| ៥.វេជ្ជ. សុខ ប៉ូ | អនុប្រធានន.មន្ទីរពេទ្យ<br>នៃក្រសួងសុខាភិបាល | អនុប្រធាន |
| ៦.លោក រស់ ឈុនអៀង | ប្រធានការិ.សេដ្ឋកិច្ច និងហិរញ្ញប្បទានសុខាភិបាល<br>នៃក្រសួងសុខាភិបាល | សមាជិក |
| ៧.សាស្ត្រាចារ្យ ដួង ប៊ុណ្ណ | សមាជិកក្រុមប្រឹក្សាភិបាលនៃមន្ទីរពេទ្យព្រះកុសុមៈ<br>នៃក្រសួងសុខាភិបាល | សមាជិក |
| ៨.វេជ្ជ. អ៊ា ប៉ | អ្នកស្រាវជ្រាវវិទ្យាស្ថានសុខភាពសាធារណៈ<br>នៃក្រសួងសុខាភិបាល | សមាជិក |
| ៩.វេជ្ជ. ទត ប៉ូឡារី | អនុប្រធានការិ.តាវកាលិក នៃប.ស.ស<br>នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១០.លោក គង់ ផេងលី | អនុប្រធានការិ.ជំរះបញ្ជី នៃន.ថវិកា និងហិរញ្ញវត្ថុ<br>នៃក្រសួងសុខាភិបាល | សមាជិក |
| ១១.វេជ្ជ. ប៊ុន សំណាង | មន្ត្រីការិ.សេដ្ឋកិច្ច និងហិរញ្ញប្បទានសុខាភិបាល<br>នៃក្រសួងសុខាភិបាល | សមាជិក |
| ១២.លោក ហេង សុផាន់ណារិទ្ធ | មន្ត្រីបេឡាជាតិរបបសន្តិសុខសង្គម<br>នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១៣.លោក ដួង សុខា | មន្ត្រីបេឡាជាតិរបបសន្តិសុខសង្គម<br>នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១៤.លោក ម៉ៃឃើល ស្តាល់ | អ្នកជំនាញការ នៃប.ស.ស<br>នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |

**ប្រការ ២-**

គណៈកម្មការមានតួនាទី ភារកិច្ច និងបេសកកម្មដូចតទៅ៖

១. ធ្វើការសិក្សាស្រាវជ្រាវ និងកំណត់ជ្រើសរើសយកយន្តការទូទាត់ថ្លៃសេវាសុខាភិបាល និងតម្លៃសេវាមូលដ្ឋានសុខាភិបាល ។

២. កំណត់ប្រភេទក្រុមជម្ងឺ និងស្នើតម្លៃសេវាដែលត្រូវទូទាត់ទៅតាមក្រុមជម្ងឺនីមួយៗ និងកំណត់ពីយន្តការទូទាត់ថ្លៃសេវាដល់មូលដ្ឋានសុខាភិបាល ដែលបានចុះកិច្ច-សន្យា ជាមួយ ប.ស.ស ។

៣. កំណត់លក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើសមូលដ្ឋានសុខាភិបាល ដែលបានចុះកិច្ចសន្យាជាមួយ ប.ស.ស យន្តការត្រួតពិនិត្យគុណភាពសេវា និងបែបបទទទួលបានសេវាដល់សមាជិក ប.ស.ស។

៤. កំណត់បែបបទ និងនីតិវិធីដើម្បីឲ្យសមាជិក ប.ស.ស ទទួលបានសេវាសុខា-ភិបាល និងទាមទារការទូទាត់សេវាសុខាភិបាល។

៥. សហការ និងសម្របសម្រួលជាមួយអង្គភាព ឬ ស្ថាប័នរដ្ឋ និងអង្គការជាតិ-អន្តរជាតិពាក់ព័ន្ធនានា ក្នុងការបំពេញភារកិច្ចទាំងអស់ខាងលើ។

**ប្រការ ៣-**

គណៈកម្មការនេះចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

រាល់ការចំណាយពាក់ព័ន្ធការអនុវត្តមុខងាររបស់គណៈកម្មការ និងលាភការរបស់សមាជិកគណៈកម្មការត្រូវកំណត់ដោយសេចក្តីសម្រេចក្រុមប្រឹក្សាភិបាល នៃបេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**ប្រការ ៤-**

គណៈកម្មការនេះបញ្ចប់ភារកិច្ចក្រោយពេលសិក្សាស្រាវជ្រាវ រៀបចំយន្តការនៃការទូទាត់សេវាសុខាភិបាលបានចប់សព្វគ្រប់។

**ប្រការ ៥-**

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១២

**រដ្ឋមន្ត្រី**
**ក្រសួងសុខាភិបាល**

**ម៉ម_ប៊ុនហេង**

**រដ្ឋមន្ត្រី**
**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**វង សុត**

ចម្លងជូន
- ខុទ្ទកាល័យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ខុទ្ទកាល័យក្រសួងសុខាភិបាល
- ក្រុមប្រឹក្សាភិបាលនៃប.ស.ស
- ក្រុមប្រឹក្សាបច្ចេកទេស (ក.ប.ស.ស.)
- បេឡាជាតិរបបសន្តិសុខសង្គម
  "ដើម្បីជូនជ្រាប"
- អង្គភាពសាមី
- សាមីខ្លួន
  "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ
- រាជកិច្ច